**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនចាន់រីទ្រីនិងតំណាងកម្មករនិយោជិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានចាន់រីទ្រីមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ចំនួន ៦០នាក់(ស្រី១៣នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ រហូតដល់ទី០៨ ខែឧសភា ឆ្នាំ២០២១ នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកបានទទួលស្គាល់នូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន៦០ដុល្លារអាមេរិកក្នុងមួយខែសំរាប់កម្មករនិយោជិកម្នាក់ៗ។ អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ១២រោចខែផល្គុន ឆ្នាំជូតទោស័កព.ស២៥៦៤
សៀមរាប ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

ហត្ថលេខា និងត្រា នាយិកា

តំណាងកម្មករនិយោជិក

CHANREY TREE
KINGDOM OF CAMBODIA

ជុនតាប់